ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះវិហារ

សំណុំរឿងព្រហ្មទណ្ឌលេខ ២៣៩
ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ ២៧២
ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១
សាលក្រមព្រហ្មទណ្ឌ
លេខ ៥០ (ច)
ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តព្រះវិហារ

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោងប្រាំបួនព្រឹក ដោយមានសមាសភាពៈ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ
លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះវិហារ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះវិហារ

ដើម្បីធ្វើការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៣៩ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២១ ដែលមានជនជាប់ចោទៈ

ឈ្មោះ[redacted]គីមរ៉ុង ភេទប្រុស អាយុ៣៦ឆ្នាំ ឆ្នាំ១៩៨៥ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិចំការអណ្ដូង ឃុំចំការអណ្ដូង ស្រុកចំការលើ ខេត្តកំពង់ចាម មានអាសយដ្ឋានបច្ចុប្បន្ននៅភូមិដំណា[redacted] ឪពុកឈ្មោះ[redacted] (រស់) ម្ដាយឈ្មោះ [redacted] (រស់) ប្រពន្ធឈ្មោះ [redacted](រស់) មានកូនចំនួន ០៤នាក់ (កូនតូចអាយុ២ឆ្នាំ ០៦ខែ) ប្រវត្តិនៃការផ្ដន្ទាទោសពីមុនដោយតុលាការ "គ្មាន" ជានីតិជន។ (ក្នុងឃុំលេខ ១៥០៣/២២.០៥.២០២១)

ត្រូវជាប់ចោទពីបទ រំលោភសេពសន្ថវៈ (មានស្ថានទម្ងន់ទោសទាក់ទងនឹងអាយុជនរងគ្រោះ) ប្រព្រឹត្តនៅភូមិដំណាក់ចិន ឃុំរស្មី ស្រុករវៀង ខេត្តព្រះវិហារ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងត្រូវផ្ដន្ទាទោសតាមបញ្ញត្តិ មាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

ដែលមាន **លោក[redacted]សាំង** ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទខាងលើ

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]យឿន ភេទស្រី អាយុ៤៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងទន្ទឹម ឃុំរមទម ស្រុករវៀង ខេត្តព្រះវិហារ

ជនរងគ្រោះឈ្មោះ [redacted]សុខយៀន ភេទស្រី អាយុ១៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំ[redacted]

ដែលមានលោកស្រី [redacted] **សូនី** និងលោក [redacted]**សារ៉ាឌុច** ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១១៩៣ ដ.ស.ព ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រះវិហារ

-បានឃើញដីកាដំណោះស្រាយលេខ ២៧២៦ ព្រ.ទ/២១ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះវិហារ

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៧៥៦/២០២១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តព្រះវិហារ

-បានឃើញដីកាសម្រេចដាក់រឿងទៅជំនុំជម្រះលេខ ៨១៥/២០២១ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តព្រះវិហារ

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:

កាលពីថ្ងៃ១៥ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១៥ និង ០០ នាទី មានករណីរំលោភសេពសន្ថវៈ (មានស្ថានទម្ងន់ទោសទាក់ទងនឹងអាយុជនរងគ្រោះ) មួយកើតឡើង ស្ថិតនៅភូមិដំណាក់ចិន ឃុំរស្មី ស្រុករវៀង ខេត្តព្រះវិហារ ដែលបង្កឡើយដោយជនល្មើសឈ្មោះ [redacted]គីមរ៉ុង ភេទប្រុស អាយុ៣៦ឆ្នាំ បានធ្វើសកម្មភាពចាប់រំលោភទៅលើជនរងគ្រោះឈ្មោះ [redacted]សុខយៀន ភេទស្រី អាយុ១៨ឆ្នាំ នៅផ្ទះរបស់ជនត្រូវចោទផ្ទាល់រាល់ពេលដែលប្រពន្ធមិននៅផ្ទះ។

## នាពេលសាកសួរ

-ជនជាប់ចោទឈ្មោះ[redacted] គីមរ៉ុង បាននាពេលសវនាការថា កាលពីដើមខែមករា ឆ្នាំ២០២១ ប្រពន្ធខ្លួនបានហៅប្អូនស្រីឈ្មោះ [redacted] សុខយៀន មកជួយមើលក្មួយ និងជួយធ្វើចំការនៅផ្ទះស្ថិតក្នុងភូមិដំណាក់ចិន ពិតមែន។ ខ្លួនមិនទទួលស្គាល់ការចោទប្រកាន់ឡើយ។ ដំបូងលើកទី១ ខ្លួនបានចាប់ដៃនៅផ្ទះ ហើយទាញនាង ([redacted] សុខយៀន) ទៅក្រោយផ្ទះ រួចបានចាប់អោបថើបនាង នាងក៏រើ ខ្លួនមិនបានធ្វើអ្វីនាងទៀតឡើយ ហើយក៏ដើរចេញទៅ។ ថ្ងៃកើតក្រោយមកទៀត លើកទី២ នៅក្រោយផ្ទះដដែល ខ្លួនបានអោបចង្កេះនាង និងថើបនាង នាងរើ ខ្លួនមិនបានធ្វើអ្វីទៀតឡើយ។ បន្តមកទៀត លើកទី៣ នាងកំពុងលាងចាន ខ្លួនបានធ្វើសកម្មភាពដដែល អោបថើប ប៉ុន្តែលើកនេះខ្លួនបានផ្តួលទៅដី ស្រាតខោ នាងក៏សុំអង្វរ ខ្លួនក៏បញ្ឈប់មិនបានចាប់រំលោភឡើយ។ លើកទី៤ នៅចំការ នាងកំពុងស្រោចទឹកដំណាំ ខ្លួនបានធ្វើសកម្មភាពដដែល អោបថើប ស្រាតខោនាង នាង



Scanned with CamScanner

សុំអង្វរ ខ្លួនក៏បញ្ឈប់។ លើកទី៥ និងលើកទី៦ ខ្លួនបានធ្វើសកម្មភាពដូចរាល់ដងនៅចំការ ខ្លួនបានស្រាតខោនាង នាងសុំអង្វរ ខ្លួនក៏បញ្ឈប់។ ពេលខ្លួនស្រាតខោនាង ខ្លួនបានចាប់ផ្តួលនាងនឹងដី។ នាងជាជនរងគ្រោះ នាងឈ្មោ[redacted] សុខឃៀន ហៅ ផុន។ ខ្លួនបានធ្វើសកម្មភាពនេះចំនួន ០៦ដង។ ឈ្មោះ[redacted]សុខឃៀន ជាប្អូនស្រីថ្លៃរបស់ខ្លួន គាត់រស់នៅជាមួយខ្លួន និងប្រពន្ធខ្លួន បានចំនួនប្រហែល ០៣ ទៅ ០៤ខែ។ ខ្លួនបានតែស្រាតខោ និងអោបថើបតែប៉ុណ្ណោះ។ ខ្លួនមិនបានយកប្រដាប់ភេទខ្លួនចេញពិខោទេ។ ប្រដាប់ភេទខ្លួនមិនបានរឹងឡើយ។ ខ្លួនបានប្រ[redacted] បានចំនួន ០១ដង។ ខ្លួនស្រាតខោគាត់ គាត់អង្វរខ្លួនថា នាងអត់ធ្វើបែបនេះទេ ទើបខ្លួនបញ្ឈប់។ ខ្លួនមានអារម្មណ៍ផ្លូវភេទ ចង់រួមភេទ។ នាងមិនបានស្លៀកលីអូទេ។ ខ្លួនស្រាតខោនាងត្រឹមជង្គង់។ រាល់ដងនេះ ខ្លួនមិនបានយកប្រដាប់ភេទខ្លួន ដាក់ចូលក្នុងប្រដាប់ភេទជនរងគ្រោះឡើយ។ ចំនួន ០៦ដង ខ្លួនជាចាប់បង្ខំទាំងអស់ តែមិនបានដាក់ប្រដាប់ភេទចូលឡើយ។

-ជនរងគ្រោះឈ្មោ[redacted] សុខឃៀន បានឆ្លើយបំភ្លឺនាពេលសវនាការថា ខ្លួនមានអាយុ១៤ឆ្នាំ។ ខ្លួនមានវដ្តរដូវហើយ។ ជនល្មើសត្រូវជាបងថ្លៃខ្លួន។ ខ្លួនរស់នៅជាមួយគាត់តាំងពីខែ១ ដល់ខែ៤។ សកម្មភាពគាត់ធ្វើនេះ ចាប់តាំងពីខែ១។ គាត់ធ្វើសកម្មភាពចាប់រំលោភខ្លួន ចាប់តាំងពីខ្លួនបានទៅរស់នៅជាមួយគាត់បានចំនួន ០២ ទៅ ០៣ថ្ងៃដំបូង។ សមាជិកក្នុងគ្រួសារមានចំនួន ០៧នាក់ មាន បងថ្លៃ បងស្រីខ្លួន កូនចំនួន ០៤នាក់ មានអាយុ១៣ឆ្នាំម្នាក់ អាយុ៦ឆ្នាំម្នាក់ អាយុ៣ឆ្នាំម្នាក់ ២ឆ្នាំម្នាក់។ ថ្ងៃដំបូងបងថ្លៃខ្លួនបានធ្វើសកម្មភាពចាប់ខ្លួនពេលកំពុងលាងចាន ខ្លួនបានស្រែកឲ្យគេជួយ ប៉ុន្តែគ្មានអ្នកជួយ។ ខ្លួនស្គាល់ប្រដាប់ភេទមនុស្ស (ពងក្ក)។ គាត់បានដាក់ប្រដាប់ភេទគាត់ដាក់ចូលក្នុងប្រដាប់ភេទខ្លួន សកម្មភាពគាត់បានដាក់ប្រដាប់ភេទចូលក្នុងប្រដាប់ភេទខ្លួន រុញចុះរុញឡើង គាត់ជាអ្នកស្រាតខោខ្លួនគាត់។ គាត់ដាក់ចូលប្រហែ[redacted] ក្រោយមកប្រដាប់ភេទបងថ្លៃ[redacted]ចេះទឹក។ ក្រោយពីធ្វើសកម្មភាពរួច គាត់គម្រាមថា បើប្រាប់អ្នកណា គាត់សម្លាប់ចោល។ លើកទី២ នៅកន្លែងងូតទឹក។ ខ្លួនបានធ្វើសកម្មភាពដដែល ដោយប្រចាប់ដោះ អោបថើប បម្រុងធ្វើសកម្មភាពចាប់រំលោភខ្លួនដដែល ប៉ុន្តែខ្លួនសុំអង្វរគាត់ គាត់បានបញ្ឈប់សកម្មភាព គាត់មិនបានដាក់ប្រដាប់ភេទគាត់ចូលក្នុងប្រដាប់ភេទខ្លួនឡើយ។ លើកទី៣ នៅកន្លែងដាំបាយ បងថ្លៃខ្លួន បានចាប់ដៃខ្លួនអូសទៅក្រោយផ្ទះ និងចាប់អោបថើបខ្លួន ខ្លួនក៏សុំអង្វរគាត់ គាត់មិនបានដាក់បញ្ចូលប្រដាប់ភេទគាត់ចូលក្នុងប្រដាប់ភេទខ្លួនឡើយ។ លើកទី៤ នៅកន្លែងដាំបាយដដែល និងអូសដៃទៅក្រោយ រួចស្រាតខោខ្លួន ហើយគាត់ដាក់ប្រដាប់គាត់ចូលក្នុងប្រដាប់ភេទខ្លួនដូចលើកដំបូង។ ប្រដាប់ភេទខ្លួនមានឈាមហូរដដែល។ លើកទី៥ នៅចំការសណ្តែក គាត់អូសដៃខ្លួន គាត់ធ្វើសកម្មភាពដូចរាល់ដង អោបថើប និងបានដាក់ ប្រដាប់ភេទចូលក្នុងប្រដាប់ភេទខ្លួន។ លើកទី៦ មិនបានសម្រេចឡើយ។ គាត់ធ្វើសកម្មភាពចំនួន ០៧ដង។ លើកទី៧ នៅចំការជំឡុង គាត់បានដាក់ប្រដាប់ភេទគាត់ចូលក្នុងប្រដាប់ភេទខ្លួន។ លើកចុងក្រោយនេះ



Scanned with CamScanner

គាត់មិនបានគម្រាមឡើយ។ គាត់គម្រាមដោយយកកាំបិតមកគម្រាមថា បើប្រាប់គេ សម្លាប់ចោលភ្លាម។ ក្នុងមួយខែគាត់ធ្វើសកម្មភាព ០២ដង។ គ្រប់ពេលធ្វើសកម្មភាពរំលោភនេះ បងស្រីខ្លួនមិនបាននៅផ្ទះឡើយ។ សកម្មភាពនៅចំការ គឺនៅតែ០២នាក់ទេ។ សកម្មភាពចំនួន ០៧ដង បានសម្រេចបានដាក់ប្រដាប់ភេទគាត់ចូលក្នុងប្រដាប់ភេទខ្លួនចំនួន ០៣ដង និងមិនបានចំនួន ៤ដង។ គាត់រំលោភហើយ បានយកកាំបិតមកគម្រាម។ ពេលធ្វើសកម្មភាពរំលោភ គាត់មិនបានយកកាំបិតមកគម្រាមទេ។ ខ្លួនបានស្រែកដែរ តែដោយសារស្ងាត់ពេក ពុំមានអ្នកជួយឡើយ។ លើកចុងក្រោយទី៧ ទើបខ្លួនបានប្រាប់បងស្រី។ រាល់ដងមិនបានប្រាប់ទេ ព្រោះខ្លាចគាត់។ នេះជាលើកទី១សម្រាប់ការនៅជាមួយមនុស្សប្រុស (រួមភេទ)។ ប្រដាប់ភេទខ្លួនមានរលាក និងរមាស់។ បច្ចុប្បន្ននេះខ្លួនធ្លាក់សហើយ។ មុនគាត់រំលោភមិនបានធ្លាក់សឡើយ តែគាត់រំលោភរួច ធ្លាក់ស។ ពីកន្លែងរំលោភ ទៅផ្ទះ មានចំងាយឆ្ងាយ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ាត បានឆ្លើយបំភ្លឺនាពេលសវនាការថា ខ្លួនបានទទួលដំណឹងនេះ តាមរយៈម្តាយក្មេងស្រីរងគ្រោះ។ ក្រោយទទួលពត៌មាន ខ្លួនបានទៅដាក់ពាក្យបណ្តឹងតែម្តង។ ក្រោយមកខ្លួនបានហៅក្មួយស្រីមកផ្ទះខ្លួន។

-លោកស្រី [redacted] សូនី ជាមេធាវីការពារសិទ្ធិឲ្យជនរងគ្រោះ បានស្នើសុំនាពេលសវនាការថា ស្នើសុំឲ្យម្តាយបង្កើតក្មេងស្រីជនរងគ្រោះតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីវិញ។

-ម្តាយជនរងគ្រោះឈ្មោះ[redacted] យឿន អាយុ៤៩ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិដំណាក់ចិន ឃុំរស្មី ស្រុករវៀង ខេត្តព្រះវិហារ បានឆ្លើយបំភ្លឺនាពេលសវនាការ កូនស្រីខ្លួនបានខលទូរស័ព្ទប្រាប់ខ្លួនថា បងថ្លៃបានចាប់រំលោភខ្លួន។ ខ្លួនមិនចាំពេលខលប្រាប់នោះឡើយ។ ពេលនោះ ខ្លួនធ្វើការនៅប្រទេសម៉ាឡេ។ កូនស្រីខ្លួនមិនបានប្រាប់ថា បងថ្លៃវាចាប់រំលោភបានប៉ុន្មានដងឡើយ។ ក្រោយទទួលព័ត៌មានភ្លាម ខ្លួនបានប្រាប់ទៅប្អូនប្រុសខ្លួន ដើម្បីដាក់ពាក្យបណ្តឹង។ ខ្លួនមិនទាមទារសំណងអ្វីឡើយ ស្នើសុំឲ្យតុលាការចាត់ការតាមច្បាប់។

-សាក្សីឈ្មោះ[redacted]សុខឃីម ភេទស្រី អាយុ៣១ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិដំណាក់ចិន ឃុំរស្មី ស្រុករវៀង ខេត្តព្រះវិហារ បានឆ្លើយបំភ្លឺនាពេលសវនាការថា ខ្លួនត្រូវជាប្រពន្ធរបស់ជនជាប់ចោទ។ នៅក្នុងរឿងហេតុ ខ្លួនពុំបានដឹងច្បាស់ឡើយ ហើយក៏ពុំបានចាប់អារម្មណ៍ដែរ។ ជារៀងរាល់ថ្ងៃ ខ្លួនចេញទៅលក់ដូរ(លក់នំកូនក្មេង) ខាងក្រៅ ខ្លួនចូលផ្ទះតែពេលម៉ោងបាយថ្ងៃតែប៉ុណ្ណោះ ក្រោយហូបបាយរួច ខ្លួនចេញទៅលក់ដូរទៀតហើយ។ ខ្លួនទើបតែដឹងរឿងលើកចុងក្រោយនេះ លើកទី៧ ដោយប្អូនស្រីបានប្រាប់ខ្លួន ថាប្តីខ្លួនរកចាប់រំលោភលើរូបគាត់។ ភ្លាមៗ នោះ ខ្លួនខឹង បន្ទាប់ពីបានដឹងរឿងភ្លាម ខ្លួនបានសួរទៅប្តីខ្លួនថា "ម្តេចបានធ្វើចឹង" ប្តីខ្លួនតប "ខ្លួនពិតជាបានធ្វើបែបនេះមែន ប៉ុន្តែមិនបានស៊ីជម្រៅឡើយ (រួមភេទ) គ្រាន់តែអោបថើប"។ មូលហេតុដែលខ្លួនសួរនាំ ហើយប្អូន



Scanned with CamScanner

ស្រីខ្លួនប្រាប់ខ្លួននោះ ដោយនៅថ្ងៃនោះ ខ្លួនឃើញប្អូនស្រីខ្លួនមានមុខមាត់ស្លេកស្លាំង អារប្រលាក់ដីខាងខ្នង រួចបានខ្លួនសួរគាត់ ទើបដឹងរឿងហេតុនេះ។

-ក្រឡាបញ្ជីអានឯកសារពិនិត្យរំលោភផ្លូវភេទលេខ ១៩/២១ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ របស់ជនរងគ្រោះឈ្មោះ[redacted] សុឃៀន ហៅ ស្រីញ៉ាញ់ ដែលចេញដោយមន្ទីរសុខាភិបាលខេត្តព្រះវិហារ។

-មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ បានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានបញ្ចប់ការសួរដេញដោលនាពេលសវនាការនេះ និងបានសិក្សាទៅលើសំណុំរឿងនេះ ឃើញថា ពិតជាមានអំពើរំលោភទៅលើក្មេងស្រីឈ្មោ[redacted] សុខឃៀន ប្រាកដមែន ដោយផ្អែកទៅលើចម្លើយរបស់ជនជាប់ចោទបានសារភាព ខ្លួនបានអោបថើបទៅលើជនរងគ្រោះប្រាកដមែន ដោយបដិសេធថាមិនបានដាក់ប្រដាប់ភេទចូលក្នុងប្រដាប់ភេទជនរងគ្រោះ ប៉ុន្តែពិចារណាទៅលើសកម្មភាពរបស់ជនជាប់ចោទសម្តែងឲ្យឃើញថា មានចេតនារំលោភទៅលើជនជាប់ចោទរួចជាស្រេចហើយ ទោះបីជនរងគ្រោះបានសុំអង្វរក៏ដោយ ជនជាប់ចោទមានចំណង់ផ្លូវភេទហើយ ឃើញថា ជនជាប់ចោទឆ្លើយបែបនេះ ដើម្បីដោះសារតែប៉ុណ្ណោះ បើពិនិត្យទៅលើចម្លើយរបស់ជនរងគ្រោះ ឯកសារពិនិត្យការរំលោភផ្លូវភេទ ម្យ៉ាងទៀតចម្លើយរបស់ជនរងគ្រោះ និងចម្លើយរបស់ជនជាប់ចោទមានភាពស៊ីសង្វាក់គ្នា ស្តែងឲ្យឃើញថា ជនជាប់ចោទពិតជាបានធ្វើសកម្មភាពរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងអាយុជនរងគ្រោះទៅលើជនរងគ្រោះពិតប្រាកដមែន ហេតុដូច្នេះ ខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនរងគ្រោះ ស្នើសុំឲ្យតុលាការមេត្តា និងសម្រេចផ្តន្ទាទោសទៅលើជនជាប់ចោទជាអតិបរមានៃទោស។

តំណាងរយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ចម្លើយរស់ជនជាប់ចោទនាពេលសវនាការ ថាខ្លួនមិនបានប្រព្រឹត្តរំលោភសេពសន្ថវៈទៅលើជនរងគ្រោះនោះឡើយ ចម្លើយនេះជាការដោះសារដើម្បីឲ្យខ្លួនរួចផុតពីការទទួលខុសព្រហ្មទណ្ឌតែប៉ុណ្ណោះ ឃើញថា ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះថា ខ្លួនពិតជាត្រូវបានជនជាប់ចោទបានចាប់រំលោភមកលើខ្លួនជាច្រើនដង អំពើរបស់ជនជាប់ចោទបង្កព្យសនកម្មដល់ជនរងគ្រោះ និងសង្គម ហេតុដូច្នេះ តំណាងអយ្យការប្តឹងស្នើសុំរក្សាបទចោទប្រកាន់នៅដដែល និងស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិនិត្យពិចារណា និងសម្រេចផ្តន្ទាទោសទៅលើជនជាប់ចោទត្រឹមកម្រិតអតិបរមា។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីគ្រាន់តែបានធ្វើសកម្មភាពអោបថើបទៅលើជនរងគ្រោះតែប៉ុណ្ណោះ មិនបានធ្វើសកម្មភាពរំលោភបំពានផ្លូវភេទទៅលើជនរងគ្រោះឡើយ ម្យ៉ាងសកម្មភាពគ្រប់ពេលរបស់កូនក្តីខ្លួន ថាបានធ្វើសកម្មភាពរំលោភទៅលើជនរងគ្រោះ ម្តងជាពីរដង គប្បីជនរងគ្រោះប្រាប់ទៅម្តាយបីងរបស់ខ្លួន និងអ្នកដទៃ ដើម្បីដឹង



Scanned with CamScanner

អំពីរឿងហេតុនេះ ហេតុដូច្នេះស្នើសុំតុលាការពិចារណាអំពីចំណុចនេះ ខ្លួនជាមេធាវីការពារឲ្យជនជាប់ចោទស្នើសុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសឲ្យកូនក្តីខ្លួន។

-សម្តីចុងក្រោយរបស់ជនជាប់ចោទ ស្នើសុំលើកលែងទោស។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទនាពេលសវនាការ

ក្រោយពីបានស្តាប់ចម្លើយបំភ្លឺរបស់ជនរងគ្រោះនាពេលសវនាការ

ក្រោយពីបានស្តាប់ចម្លើយបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណីនាពេលសវនាការ

ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សីនាពេលសវនាការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានាដែលមានក្នុងសំណុំរឿង

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តព្រះវិហារ យល់ឃើញថា

១.តុលាការជំនុំជម្រះទទួលបានបណ្តឹងតាមដីកាដំណោះស្រាយលេខ ២៧២៦ ព្រ/ទ/២១ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះវិហារ ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ[redacted]គីមរ៉ុង ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិខាងលើ) មកតុលាការដើម្បីជំនុំជម្រះ ពីបទ រំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសទាក់ទងនឹងអាយុជនរងគ្រោះ) ប្រព្រឹត្តនៅភូមិដំណាក់ចិន ឃុំរស្មី ស្រុករវៀង ខេត្តព្រះវិហារ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។

២.ជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួនមិនបានចាប់រំលោភលើក្មេងស្រីរងគ្រោះឡើយ ខ្លួនគ្រាន់តែបានអោបថើបទៅលើជនរងគ្រោះតែប៉ុណ្ណោះ ជនជាប់ចោទបានសារភាពបន្ថែមទៀតថា ខ្លួនពិតជាមានបំណងចង់រួមភេទជាមួយនឹងក្មេងស្រីជនរងគ្រោះ ខ្លួនមិនបានរំលោភនាងដោយសារនាងសុំអង្វរ ហើយខ្លួនពិតជាបានចាប់ផ្តួលនាងប្រាកដមែន ឃើញថា ចម្លើយនេះជនជាប់ចោទឆ្លើយបដិសេធដើម្បីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌតែប៉ុណ្ណោះ បើពិនិត្យទៅលើចម្លើយរបស់ជនរងគ្រោះឃើញថា ជនជាប់ចោទបានធ្វើសកម្មភាពចាប់រំលោភសេពសន្ថវៈលើខ្លួនចំនួន ០៧លើក ជនជាប់ចោទបានរំលោភសន្ថវៈបានសម្រេចចំនួន ០៣លើក និងមិនបានសម្រេចចំនួន ០៤លើក ជនរងគ្រោះបានបំភ្លឺបន្ថែមថា គ្រប់សកម្មភាពរបស់ជនរងគ្រោះគ្រប់លើក តែងតែចាប់អោបថើបខ្លួន រួចចាប់ផ្តើមធ្វើសកម្មភាពយកប្រដាប់ភេទដាក់ចូលក្នុងប្រដាប់ភេទខ្លួនតែម្តង ឃើញថា ចម្លើយនេះជាស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទ ស្តែងឲ្យឃើញអំពីចេតនា និងសកម្មភាពរបស់ជនជាប់



Scanned with CamScanner

ចោទ ព្រមទាំងចម្លើយបំភ្លឺដើមបណ្ដឹងរដ្ឋប្បវេណី ចម្លើយបំភ្លឺរបស់សាក្សី ព្រមទាំងការពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿង ការពិនិត្យឯកសារពិនិត្យរំលោភផ្លូវភេទលេខ ១០/២១ របស់មន្ទីរសុខាភិបាលខេត្តព្រះវិហារ បានបង្ហាញថា តាមរយៈការពិនិត្យលើដងខ្លួន របស់ជនរងគ្រោះ បានឃើញស្លាកស្នាម បបូរតូចរីកធំខុសធម្មតា រន្ធព្រហ្មចារី រីកធំខុសធម្មតា សន្ទះព្រហ្មចារីមានស្នាមដាច់រហែកចាស់នៅម៉ោង ១, ៣, ៥, ៧ និងម៉ោង ១១ ឃើញថា ជនជាប់ចោទពិតជាមានចេតនា និងបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការពីបទ រំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសទាក់ទងនឹងអាយុជនរងគ្រោះ) ហេតុដូច្នេះ តុលាការមានមូលដ្ឋានគ្រប់គ្រាន់សម្រេចតាមច្បាប់បាន តាមបញ្ញត្តិមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។

៣.តាមការពិនិត្យលើសំបុត្របញ្ជាក់កំណើតលេខ ១១៣ សៀវភៅបញ្ជាក់កំណើតលេខ ០២/២០១៧ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ បានបង្ហាញថា ជនរងគ្រោះឈ្មោះ[redacted]សុខឃៀន កើតថ្ងៃទី ១២ ខែមីនា ឆ្នាំ២០០៧ ហេតុដូច្នេះគិតដល់ថ្ងៃកើតហេតុ ជនរងគ្រោះមានអាយុ ១៤ឆ្នាំ ០៩ខែ ០៣ថ្ងៃ ហេតុដូច្នេះតុលាការអាចធ្វើការពិចារណា និងសម្រេចតាមបញ្ញត្តិមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌបាន។

៤.តំណាងអយ្យការ បានស្នើសុំរក្សាបទចោទប្រកាន់នៅដដែល និងស្នើសុំឲ្យតុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់ ការស្នើសុំស្របតាមការយល់ឃើញរបស់ចៅក្រមជំនុំជម្រះ គប្បីតុលាការពិចារណា។

៥.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ ធ្វើឲ្យមានការប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម និងប៉ះពាល់រូបរាងការបុគ្គល ដែលត្រូវបានច្បាប់ការពារតាមបញ្ញត្តិមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។

៦.ជនជាប់ចោទជានីតិជនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹងខុសត្រូវពីផលវិបាកដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន និងមិនមានភស្តុតាងណាមួយ បញ្ជាក់ពីការមានវិបល្លាសស្មារតីរបស់ជនជាប់ចោទ ដូច្នេះជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះមុខច្បាប់។

៧.មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោ[redacted]គីមរ៉ុង ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ ពីបទ រំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសទាក់ទងនឹងអាយុជនរងគ្រោះ) ប្រព្រឹត្តនៅភូមិដំណាក់ចិន ឃុំរស្មី ស្រុករវៀង ខេត្តព្រះវិហារ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។

៨.ជនជាប់ចោទបានឆ្លើយដោះសារមិនព្រមសារភាពនូវអំពើល្មើសរបស់ខ្លួនឡើយ ទោះបីតុលាការបានធ្វើការស្ដាប់ចម្លើយអ្នកពាក់ព័ន្ធ ព្រមទាំងការពិនិត្យភស្តុតាង ដែលបានបញ្ជាក់ថាជនជាប់ចោទពិតជាមានចេតនា និងបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការប្រាកដមែន ហេតុដូច្នេះគប្បីតុលាការមិនពិចារណាអំពីស្ថានសម្រាលដល់ជនជាប់ចោទ និងវិនិច្ឆ័យទោសក្នុងកម្រិតក្បែរអតិបរមាឲ្យសមនឹងទង្វើរបស់ជនជាប់ចោទ។



Scanned with CamScanner

៥.ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] យឿន មិនស្នើសុំទាមទារសំណងរដ្ឋប្បវេណីឡើយ ហេតុដូច្នេះ ចំពោះសំណងរដ្ឋប្បវេណី គប្បីតុលាការមិនធ្វើការពិចារណា និងសម្រេចឡើយ។

**ហេតុដូច្នេះសាលាដំបូងខេត្តព្រះវិហារ**

**វិនិច្ឆ័យសេចក្ដី**

ផ្ដន្ទាទោសលើឈ្មោះ [redacted] គឹមរ៉ុង ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១០ (ដប់) ឆ្នាំ ពីបទ រំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសទាក់ទងនឹងអាយុជនរងគ្រោះ) ប្រព្រឹត្តនៅ ភូមិដំណាក់ចិន ឃុំរស្មី ស្រុករវៀង ខេត្តព្រះវិហារ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] គឹមរ៉ុង និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ស៊ឹម យឿន។

*បើកសិទ្ធិឲ្យភាគីប្ដឹងឧទ្ធរណ៍តាមច្បាប់។*

ថ្ងៃសុក្រ ៥រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ព្រះវិហារ, ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១

| **ក្រឡាបញ្ជីសវនាការ** | **ក្រុមប្រឹក្សាជំនុំជម្រះ** | **ក្រុមប្រឹក្សាជំនុំជម្រះ** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ៥រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ព្រះវិហារ, ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner